# តើអ្នកត្រូវការជំនួយជាមួយនឹងវិក្កយបត្របង់ថ្លៃអគ្គិសនីតាមផ្ទះរបស់អ្នកមែនទេ? សូមទូរសព្ទទៅលេខ (206) 727-8400

**Seattle City Light** នៅទីនេះចាំផ្តល់ជំនួយដល់អ្នកអំឡុងពេលគ្រោះអាសន្ននៃជំងឺរាតត្បាតកូវីដ-១៩ និងមិនកាត់ផ្តាច់ថាមពលរបស់អ្នកដោយសារការមិនបានទូទាត់ប្រាក់នោះទេក្នុងអំឡុងគ្រាអាសន្ននេះ។

## អ្វីដែលយើងអាចបម្រើជូនអ្នកបាន

អ្នកមិនចាំបាច់ទាល់តែជាពលរដ្ឋម្នាក់ ហើយអ្នកមិនចាំបាច់ផ្តល់លេខសន្តិសុខសង្គមសម្រាប់ប្រភពធនធានទាំងនេះទេ។

- ជួយអ្នកក្នុងការដាក់ពាក្យស្នើសុំ Utility Discount Program (កម្មវិធីបញ្ចុះតម្លៃលើសេវាសាធារណៈ) ដើម្បីទទួលបានការបញ្ចុះតម្លៃ 60% លើវិក្កយបត្របង់ថ្លៃអគ្គិសនីតាមផ្ទះរបស់អ្នក និង 50% លើវិក្កយបត្របង់ថ្លៃទឹក/ប្រព័ន្ធលូ/សំរាមតាមផ្ទះសម្រាប់អតិថិជនដែលមានសិទ្ធិទទួលបានតាមលក្ខខណ្ឌប្រាក់ចំណូល។
- ពន្យារពេលកាលបរិច្ឆេទផុតកំណត់លើវិក្កយបត្របង់ថ្លៃអគ្គិសនីរបស់អ្នក ហើយយើងនឹងធ្វើការសហការជាមួយអ្នកដើម្បីធ្វើគម្រោងបង់ប្រាក់។
- ឆ្លើយសំណួរអំពីវិក្កយបត្របង់ថ្លៃអគ្គិសនីរបស់អ្នក។
- ចែករំលែកគន្លឹះក្នុងការសន្សំសំចៃថាមពលដើម្បីសន្សំប្រាក់លើការទូទាត់វិក្កយបត្ររបស់អ្នក។

**ការបញ្ចុះតម្លៃ**

**60%**

**50%**

## មានការបកប្រែផ្ទាល់មាត់ជូន

- នៅពេលអ្នកហៅទូរសព្ទ អ្នកអាចនឹងជួបជាមួយបុគ្គលផ្ទាល់ ឬសារជាសម្លេង។
- ប្រសិនបើមាននរណាម្នាក់ឆ្លើយទូរសព្ទ សូមប្រាប់ពីភាសាដែលអ្នកត្រូវការជាភាសាអង់គ្លេស។
- ប្រសិនបើអ្នកឮសារជាសម្លេងរបស់យើង ឬផ្ញើអ៊ីម៉ែលមកកាន់យើង សូមប្រាប់ឈ្មោះ លេខទូរសព្ទរបស់អ្នក និងភាសាដែលអ្នកត្រូវការជាភាសាអង់គ្លេស និងជំនួយអ្វីដែលអ្នកត្រូវការ។



## ទាក់ទងមកកាន់យើង

**CUSTOMER ADVOCACY TEAM**
**(ក្រុមការងារផ្តល់ជំនួយដល់អតិថិជន)**
ទូរសព្ទ៖ **(206) 727-8400**
ពីម៉ោង **8**ព្រឹក ដល់ម៉ោង **5**ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
អ៊ីម៉ែល៖ **CityLightHelp@seattle.gov**

អតិថិជនដែលជាម្ចាស់អាជីវកម្មខ្នាតតូច៖ សូមទូរសព្ទទៅលេខ (206) 256-5200 ដើម្បីស្វែងយល់អំពីជម្រើសការទូទាត់ប្រាក់ និងការវាយតម្លៃថាមពលដោយឥតគិតថ្លៃតាមជម្រើសសម្រាប់អាជីវកម្មរបស់អ្នក។

**Seattle City Light**

seattle.gov/light